ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និងឈ្មោះសំណុំរឿង : ០៨/១០-ញូ មីងដា

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : អ៊ុង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : ទូន ស៊ីផាន់

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ញូ មីងដា (ខេមបូឌា)

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង ផ្លូវចោមចៅ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៣៥៤ ៥៦៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោកស្រី សុខ វ៉ាន់ ប្រធានរដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហព័ន្ធសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ

- សហជីពដើម្បីកម្មករ នៃរោងចក្រ ញូ មីងដា

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៥៣៣ ៨៣២ លេខទូរសារ : គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតៈ

១- លោក ឈុំ វាសនា ប្រធានសហព័ន្ធសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ

២- លោក ផា ប៊ុត ប្រធានសហជីពដើម្បីកម្មករ នៃរោងចក្រ ញូមីងដា

៣- លោក អ៊ុំ មឿន លេខាធិការសហជីពដើម្បីកម្មករ នៃរោងចក្រ ញូមីងដា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិត នៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយចំនួន ១០០០ រៀល សម្រាប់កម្មករនិយោជិតធ្វើការបន្ថែមម៉ោងនៅថ្ងៃអាទិត្យ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះការធ្វើការបន្ថែមម៉ោងនៅថ្ងៃអាទិត្យ ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគុណនឹង ២ ប៉ុន្តែ ចំពោះប្រាក់ថ្លៃបាយចំនួន ១០០០ រៀល មិនផ្តល់ឱ្យឡើយ ។

២- ថ្នាក់ដឹកនាំសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ ប្រចាំរោងចក្រនៅតែចោទប្រកាន់ថា ក្រុមហ៊ុនមានការរើសអើងចំពោះសហជីព ដូចករណីក្រុមហ៊ុនមិនឱ្យកម្មករពាក់កាតសហជីពចូលក្នុងបរិវេណរោងចក្រ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានការរើសអើងចំពោះសហជីពឡើយ ហើយក្រុមហ៊ុនក៏មិនអនុញ្ញាតឱ្យសមាជិកសហជីពទាំងអស់ពាក់កាតសហជីពនៅក្នុងរោងចក្រដែរ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៣៩ ក.ប/អក/វ.ក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១០ (វេលាម៉ោង ១៤:00 នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ លេខ ០៩៣/០៩ សកដស ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យកាន់តែល្អប្រសើរ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០៦ ចំណុច។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ០៣៩ ក.ប./អក/វ.ក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ២:00 នាទី រសៀល។

ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០២ ចំណុចនេះ បន្ថែមទៀតដោយភាគីសហជីព កម្មករនិយោជិតបានដកចំណុចវិវាទទី២ ចេញពីការទាមទារ។ ដូច្នេះ ចំណុចវិវាទដែលនៅសល់ គឺចំណុចវិវាទទី១។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាង ក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក :

១- លិខិតផ្ទេរសិទ្ធិរបស់អគ្គនាយកក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) ប្រគល់សិទ្ធិជូន លោកស្រី សុខ វ៉ាន់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០។

២- ប័ណ្ណប៉ាតង់របស់ក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) លេខ DLT 029436.2010 ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០។

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) លេខ ១៩៤២ ពណ.ចបព ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩។

៤- លិខិតលេខ ២១៥៦/០៦ គ.វ.ក របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីករណីសំណើស៊ីវិនិយោគលើគំរោងបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៦។

៥- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពដើម្បីកម្មនៃរោងចក្រ ញូ មីងដា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩។

៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ញូ មីងដា ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០។

៧- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) លេខ ៥០ កប/អក/អធក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៨។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពដើម្បីកម្មករនៃរោងចក្រ ញូ មីងដា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០០៩។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ញូ មីងដា លេខ ០៣៩ ក.ប/អក/វ.ក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ញូ មីងដា ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៥០ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៥១ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

- ក្រុមហ៊ុន ញូ មីងដា បានបើកដំណើរការ នៅខែមីនា ឆ្នាំ២០០៧ ហើយបច្ចុប្បន្ននេះ ក្រុមហ៊ុនបានជួលកម្មករនិយោជិតសរុបចំនួនប្រមាណ ១០៤៨ នាក់។

- នៅក្នុងក្រុមហ៊ុន មានសហជីពចំនួន ៣ គឺសហជីពសេរីកម្មករ សហជីពខ្មែរ និងសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ ហើយពុំទាន់មានសហជីពណាមួយមានភាពតំណាងបំផុតទេ។
- សហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ ភាគីសហជីពបានបញ្ជាក់ថា កម្មករនិយោជិតដែលជាសមាជិករបស់ខ្លួន មានចំនួនប្រមាណជា ១០៦ នាក់ ដែលបានដាក់លិខិតស្នើសុំឱ្យក្រុមហ៊ុនជួយកាត់ប្រាក់ភាគទានសហជីព នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១០។ ប៉ុន្តែ ភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតបានឯកភាពគ្នាថា ក្រោយមកភាគីក្រុមហ៊ុនបានពិនិត្យ និងផ្ទៀងផ្ទាត់ជាក់ស្តែងឃើញថា ចំនួនសមាជិកសហជីពកម្ពុជាដើម្បីសិទ្ធិកម្មករ មានត្រឹមតែ ៥៤ នាក់ប៉ុណ្ណោះ ហើយក្រុមហ៊ុនបានកាត់ប្រាក់ភាគទានជូនសហជីព នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០ ពីសមាជិកទាំង ៥៤ នាក់នោះ។

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយ ចំនួន ១០០០ រៀល សម្រាប់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ**

- ភាគីក្រុមហ៊ុនបានបញ្ជាក់នៅក្នុងសវនាការថា ក្រុមហ៊ុនឱ្យកម្មករនិយោជិតធ្វើការ ៨ ម៉ោងក្នុងមួយថ្ងៃ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ហើយថ្ងៃអាទិត្យជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍។ ចំពោះការធ្វើការបន្ថែមម៉ោង គឺចាប់ពីម៉ោង ១៦:០០ រហូតដល់ម៉ោង ១៨:០០ នាទីល្ងាច ដោយក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោងចំនួន ១០០០ រៀល។ ប្រសិនបើក្រុមហ៊ុនមានការងារឱ្យកម្មករនិយោជិតធ្វើលើសពីម៉ោង ១៨:០០ ទៅ (លើសពី ២ ម៉ោងទៅ) ក្រុមហ៊ុនផ្តល់ជូនបន្ថែម ចំនួន ៥០០ រៀលទៀត ដែលចំនួនសរុបស្មើនឹង ១៥០០ រៀល បើទោះបីជាលើសប៉ុន្មានម៉ោងក៏ដោយក្នុងមួយថ្ងៃ។
- ភាគីកម្មករនិយោជិត និងភាគីក្រុមហ៊ុនបានឯកភាពថា នៅពេលក្រុមហ៊ុនមានការងារឱ្យកម្មករនិយោជិតធ្វើនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ គឺនៅថ្ងៃអាទិត្យនេះ ក្រុមហ៊ុនបានអនុវត្តតាមគោលការណ៍ស្ម័គ្រចិត្ត។ តាមគោលការណ៍របស់ក្រុមហ៊ុន គឺកម្មករនិយោជិតធ្វើការពីម៉ោង ០៧:០០ ព្រឹក រហូតដល់ម៉ោង ១១:០០ ព្រឹក និងពីម៉ោង ១២:០០ ថ្ងៃត្រង់ រហូតដល់ម៉ោង ១៦:០០ រសៀល គឺរយៈពេល ០៨ ម៉ោង ក្នុងមួយថ្ងៃ ដោយក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលឱ្យ ២០០ ភាគរយនៃប្រាក់ឈ្នួលម៉ោងធ្វើការធម្មតា។ ភាគីទាំងពីរបានឯកភាពគ្នាថា ការធ្វើការនៅថ្ងៃអាទិត្យនេះ ជាការងារថែមម៉ោង ប៉ុន្តែ ភាគីនិយោជកពុំព្រមផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោងនៅថ្ងៃនេះទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំនួន ១០០០ រៀល ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃអាទិត្យ ពីព្រោះកម្មករនិយោជិតយល់ឃើញថា ការធ្វើការនៅថ្ងៃអាទិត្យ គឺជាការធ្វើការងារបន្ថែមម៉ោង ដូចមានចែងនៅក្នុងសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃ ទី១៨ ខែកក្កដា ឆ្នាំ២០០០។ម្យ៉ាងទៀត បទបញ្ជាផ្ទៃក្នុងរបស់

ក្រុមហ៊ុន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៨ ត្រង់ប្រការ៤ ចំណុចទី៣ ក៏ចែងដែរថា ការងារបន្ថែមម៉ោង រួមទាំងការធ្វើការនៅថ្ងៃអាទិត្យផងដែរ ។

- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំនួន ១០០០រៀល ដល់កម្មករនិយោជិត ដែលស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃអាទិត្យទេ ពីព្រោះក្រុមហ៊ុនយល់ឃើញថា សេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៨ គឺសំដៅទៅលើប្រាក់ថ្លៃបាយបន្ថែមម៉ោង នៅថ្ងៃធ្វើការធម្មតាពោលគឺ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ តែប៉ុណ្ណោះ មិនមែនសម្រាប់ការងារបន្ថែមម៉ោងនៅថ្ងៃអាទិត្យនោះទេ ។ ហេតុនេះ ក្រុមហ៊ុនមិនអាចផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោងចំនួន១០០០ រៀល ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃអាទិត្យ តាមការទាមទារបានទេ ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ញូ មីងដា ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៨ ប្រការ៤ (៣) ចែងថា *"...ការធ្វើការថែមម៉ោង...គ.អនុវត្តទៅតាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចំពោះកម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោងត្រូវទទួលបានអាហារមួយពេលដោយឥតគិតថ្លៃ ឬទទួលជាប្រាក់ ១០០០ រៀល នៅរៀងរាល់ថ្ងៃដែលពួកគេបានធ្វើការងារបន្ថែមម៉ោង ។..."*

## ហេតុផលនៃសេចក្តីសម្រេច

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំនួន ១០០០ រៀល សម្រាប់កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ**

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំនួន ១០០០ រៀល សម្រាប់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ពីព្រោះកម្មករនិយោជិតយល់ឃើញថា ការងារនៅថ្ងៃអាទិត្យ ក៏ជាការងារបន្ថែមម៉ោង ដែលក្រុមហ៊ុនត្រូវផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោងនេះ ។ ភាគីក្រុម-ហ៊ុនវិញទទួលស្គាល់ថា ការងារនៅថ្ងៃអាទិត្យ ជាការងារបន្ថែមម៉ោង ប៉ុន្តែកម្មករនិយោជិតមិនមានសិទ្ធិទទួលបានប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំនួន ១០០០ រៀល នោះទេ ពីព្រោះប្រាក់នេះផ្តល់ឱ្យសម្រាប់តែកម្មករនិយោជិតណាដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង នៅក្នុងថ្ងៃធ្វើការធម្មតាប៉ុណ្ណោះ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ធ្វើការពិចារណាថា តើកម្មករនិយោជិតដែលស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃអាទិត្យ ដែលជាការធ្វើការងារបន្ថែមម៉ោង មានសិទ្ធិទទួលបានប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ដែរឬទេ?

មាត្រា ១៣៧ នៃច្បាប់ស្តីពីការងារ ចែងថា " *ក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោង ក្នុងមួយអាទិត្យឡើយ ។* "

មាត្រា១៤៧ នៃច្បាប់ស្តីពីការងារ ចែងថា "*ការឈប់សំរាកប្រចាំសប្តាហ៍ត្រូវមានថិរវេលាអប្បបរមាម្ភៃបួនម៉ោងបន្តបន្ទាប់គ្នា ។ តាមគោលការណ៍ ត្រូវអោយឈប់នៅថ្ងៃអាទិត្យសំរាប់កម្មករនិយោជិតទាំងអស់ ។*"

តាមអត្ថន័យនៃមាត្រា ១៣៧ និង មាត្រា ១៤៧ នៃច្បាប់ស្តីពីការងារខាងលើនេះ ថិរវេលាធ្វើការធម្មតារបស់កម្មករនិយោជិតមិនត្រូវលើសពី ៨ ម៉ោងក្នុងមួយថ្ងៃ ឬ ៤៨ ម៉ោងក្នុងមួយសប្តាហ៍ឡើយ ហើយជាគោលការណ៍ ថ្ងៃអាទិត្យ ជាថ្ងៃសម្រាកប្រចាំសប្តាហ៍ ។

ក្នុងករណីនេះក្រុមហ៊ុន ញូ មីងដា តម្រូវឱ្យកម្មករនិយោជិតធ្វើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ៨ ម៉ោងក្នុងមួយថ្ងៃ រឺ ស្មើនឹង ៤៨ ម៉ោងក្នុងមួយសប្តាហ៍ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នេះ គឺជាថិរវេលាធ្វើការធម្មតារបស់កម្មករនិយោជិត បើយោងតាមមាត្រា ១៣៧ នៃច្បាប់ស្តីពីការងារ ។ ដូចនេះ ការដែលនិយោជកសំណូមពរឱ្យកម្មករនិយោជិតធ្វើការនៅថ្ងៃអាទិត្យ និងដោយមានការស្ម័គ្រចិត្តយល់ព្រមពីកម្មករនិយោជិតនោះនាំឱ្យការងារនោះ ជាការងារបន្ថែមម៉ោង ។

សេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ចំណុចទី៤ ចែងថា : " *កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ។* "

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញផងដែរថា បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ញូ មីងដា ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៨ ប្រការ៤ (៣) ចែងថា "*...ការធ្វើការថែមម៉ោង...គ.អនុវត្តទៅតាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចំពោះកម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង ត្រូវទទួលបានអាហារមួយពេលដោយឥតគិតថ្លៃ ឬទទួលជាប្រាក់ ១០០០ រៀល នៅរៀងរាល់ថ្ងៃដែលពួកគេបានធ្វើការងារបន្ថែមម៉ោង ។...*"

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១៤/០៨-វ៉ាយ ចិច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបកស្រាយថា " *កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ដែលលើសពីថ្ងៃ និងម៉ោងធ្វើការធម្មតា ជាការងារបន្ថែមម៉ោង ។ ដូច្នេះ កម្មករនិយោជិតត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១០០០ រៀល សម្រាប់មួយថ្ងៃ តាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ។*"

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ គឺកម្មករនិយោជិតដែលស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃអាទិត្យ ដែលលើសពីថ្ងៃ និង

ម៉ោងធ្វើការធម្មតា ជាការធ្វើការងារបន្ថែមម៉ោង ត្រូវទទួលបានប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំនួន ១០០០រៀល សម្រាប់មួយថ្ងៃនោះ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំនួន ១០០០ រៀល ដល់កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ដែលជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅនេះ

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ :** បង្គាប់ឱ្យនិយោជក ផ្តល់ប្រាក់ថ្លៃបាយបន្ថែមម៉ោង ចំនួន ១០០០ រៀល ដល់កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ដែលជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : អ៊ុំ សុទ្ធី

ហត្ថលេខា: ----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : ឡូន ស៊ីផាន់

ហត្ថលេខា: ----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : ម៉ែន ម៉ុនណា

ហត្ថលេខា: ----------------------------

THE ARBITRATION COUNCIL